**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សាររំលែកមរណទុក្ខ

**សូមគោរពជូន**
**លោកជំទាវ លាង ឡូចឆេង និងក្រុមគ្រួសារ ចំពោះមរណភាព ឯកឧត្តម ហ៊ុន ណេង**
**សមាជិកអចិន្ត្រៃយ៍រដ្ឋសភា និងជាអ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម**

លោកជំទាវជាទីគោរពរាប់អាន!

យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីរន្ធត់ តក់ស្លុតឥតឧបមា និងក្តុកក្តួលរំជួលចិត្ត សោកស្តាយជាពន់ពេកក្រោយពីបានទទួលដំណឹងថា **ឯកឧត្តម ហ៊ុន ណេង** សមាជិកអចិន្ត្រៃយ៍រដ្ឋសភា និងជាអ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម បានទទួលមរណភាពកាលពីថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ០៦:២៥ នាទីល្ងាច ក្នុងជន្មាយុ ៧២ឆ្នាំ ដោយរោគាពាធ។

ក្នុងវេលាពោរពេញដោយក្តីរំជួលចិត្តចំពោះមរណទុក្ខដ៏ក្រៀមក្រំបំផុតនេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវសេចក្តីសោកស្តាយស្រណោះ អាឡោះអាល័យរកទីបំផុតគ្មាន ចំពោះមរណភាពរបស់ **ឯកឧត្តម ហ៊ុន ណេង** ដែលជាការបាត់បង់នូវស្វាមី ឪពុក ឪពុកក្មេក និងជីតាជាទីស្រឡាញ់ដ៏ឧត្តុង្គឧត្តម ប្រកបដោយព្រហ្មវិហារធម៌។ មរណភាពរបស់ **ឯកឧត្តម ហ៊ុន ណេង** គឺជាការបាត់បង់យ៉ាងធំធេងនូវឥស្សរជនជាន់ខ្ពស់មួយរូប ដែលមួយជីវិតរបស់ **ឯកឧត្តម** បានបូជាទាំងកម្លាំងកាយនិងចិត្ត ប្រាជ្ញា ស្មារតី ក្នុងការបម្រើជាតិ សាសនា ព្រះមហាក្សត្រ និងប្រជាជនកម្ពុជាយ៉ាងប្ដូរផ្ដាច់បំផុត។

ស្ថិតក្នុងបរិយាកាសដ៏មហាក្រៀមក្រំបំផុតនេះ យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធរបស់ **ឯកឧត្តម ហ៊ុន ណេង** សូមបានអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវ ព្រមទាំងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ៕

ថ្ងៃ ព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ**
រដ្ឋមន្ត្រី

ហ៊ុំ-សុខា

ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh